ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៣ ❋ ៤៤

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ៣៦៤ ធទឧ

# សេចក្តីជូនដំណឹង

## ស្តីពី ស្ថានភាពអាកាសធាតុនៅព្រះរាជាណាចក្រកម្ពុជា

បន្ទាប់ពីបានធ្វើការតាមដាន និងព្យាករណ៍លើស្ថានភាពអាកាសធាតុរួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា ៖ ក្នុងរយៈពេលពី 02 ទៅ 03 ថ្ងៃខាងមុខ នឹងមានប្រព័ន្ធសម្ពាធទាបមួយ ( ITCZ ) កើតឡើង និងអូសបន្លាយកាត់ពីលើអាងទន្លេមេគង្គក្នុងប្រទេសថៃ និងប្រទេសឡាវ ។ ប្រព័ន្ធសម្ពាធទាបនេះ នឹងមានឥទ្ធិពលមកលើព្រះរាជាណាចក្រកម្ពុជា ដោយបង្កឱ្យមានភ្លៀងធ្លាក់ពីបង្គួរទៅច្រើន ចាប់ពីថ្ងៃទី 25 ដល់ថ្ងៃទី 28 ខែសីហា ឆ្នាំ 2014 នៅតាមបណ្តារាជធានី-ខេត្ត មួយចំនួនដូចជា ៖

- រាជធានីភ្នំពេញ កណ្តាល កំពង់ស្ពឺ ព្រៃវែង កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី រតនគិរី ព្រះវិហារ និងខេត្តឧត្តរមានជ័យ នឹងមានភ្លៀងធ្លាក់ច្រើន ។
- ខេត្តតាកែវ ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប កំពង់ធំ កោះកុង ព្រះសីហនុ កំពត និងខេត្តកែប នឹងមានភ្លៀងធ្លាក់ពីបង្គួរទៅច្រើន ។

ការធ្លាក់ភ្លៀងនៅតាមបណ្តារាជធានី-ខេត្ត ដូចបានជម្រាបជូនខាងលើ អាចបង្កឱ្យមានជំនន់ទឹកភ្លៀងនៅតាមតំបន់ទំនាបជាប់នឹងផ្លូវទឹក ពិសេសខេត្តកំពង់ស្ពឺ និងកំណាត់ផ្លូវជាតិលេខ 4 ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន និងបង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ ចំពោះស្ថានភាពអាកាសធាតុខាងលើនេះ ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

*រាជធានីភ្នំពេញ ថ្ងៃទី 23 ខែសីហា ឆ្នាំ ២០១៤*

**រដ្ឋមន្ត្រី**

**លឹម គានហោ**

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh